សុន្ទរកថា
ឯកឧត្តម សុខ ចិន្តាសោភា ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
ក្នុងពិធីចូលកាន់តំណែង ជារដ្ឋមន្ត្រីក្រសួងការបរទេស
និង សហប្រតិបត្តិការអន្តរជាតិ
ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣

---------------------------------

- ***សូមគោរព ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន***
- ***ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភា រដ្ឋសភា***
- ***ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ លោក លោកស្រី និងអង្គពិធី ទាំងមូលជាទីស្រលាញ់រាប់អាន!***

ជាកិច្ចចាប់ផ្តើម ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះ សម្តែងនូវអំណរគុណ និង ការគោរពដឹងគុណដ៏ជ្រាលជ្រៅបំផុត ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** ដែលបានផ្តល់នូវសេចក្តីទុកចិត្ត តែងតាំងរូបខ្ញុំ **ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**។ ភារកិច្ចដ៏ឧត្តុង្គឧត្តម និងបេសកកម្មដ៏ថ្លៃថ្លានេះ គឺបានផ្តល់កិត្តិយសដ៏ធំធេងណាស់សម្រាប់ក្រុមគ្រួសារនិងសម្រាប់រូបខ្ញុំផ្ទាល់ ក្នុងការបម្រើជាតិមាតុភូមិ។ សម្រាប់រូបខ្ញុំ គ្មានបេសសកកម្មបម្រើជាតិណាដែលផ្តល់កិត្តិយស ខ្ពង់ខ្ពស់ និង ធំធេងជាងបេសកកម្មជាតំណាងរបស់ជាតិនៅលើឆាកអន្តរ-ជាតិ នោះឡើយ ។ ប៉ុន្តែទន្ទឹមនេះ ភារកិច្ច និងបេសកកម្មដ៏ឧត្តុង្គឧត្តមនេះ ក៏ជាការទទួលខុសត្រូវ និង បន្ទុកដ៏ធំធេង និង ធ្ងន់ធ្ងរ សម្រាប់រូបខ្ញុំ ជាពិសេសគឺការបន្តវេនពី ឥស្សរជនប្រមុខការទូតឆ្នើមៗ និងស្របពេលដែលវិស័យការទូតកម្ពុជាកំពុងទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ និងមានការទទួលស្គាល់នូវតួនាទីសំខាន់របស់

កម្ពុជាលើឆាកអន្តរជាតិ។ ការណ៍នេះ ជាកត្តាដែលតម្រូវឱ្យខ្ញុំត្រូវបន្តនិរន្តរភាព នៃមរតកការទូតដ៏ពិសិដ្ឋទាំងនេះ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

មរតកការទូតដ៏ថ្លៃថ្លាខាងលើ គឺកើតចេញពីការត្រួសត្រាយនូវមាគ៌ាការទូតដំបូងពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជាប្រមុខការទូតទីមួយរបស់កម្ពុជា ហើយត្រូវបានបន្តពង្រីកនិងពង្រឹង ដោយប្រមុខការទូតឆ្នើមចំនួន២រូប គឺឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន។**

ដូចដែលអង្គពិធីទាំងមូលបាន ជ្រាបជាក់ហើយថា កេរ្តិ៍ដំណែលដ៏ពិសិដ្ឋក្នុង វិស័យការទូតកម្ពុជាបានចាប់ផ្តើមឡើងនៅពេលដែល**សម្តេចតេជោ** ត្រូវបានតែងតាំងជារដ្ឋមន្ត្រីការបរទេស នៅខែមករា ឆ្នាំ ១៩៧៩ ក្នុងអាយុ ២៧ឆ្នាំ ដែលជារដ្ឋមន្ត្រីការបរទេសក្មេងជាងគេបំផុតក្នុងពិភពលោក។ សម្តេចចាប់ផ្តើមតំណែងជាប្រមុខការទូតដឹកនាំវិស័យការបរទេសកម្ពុជាចាប់តាំងពីចំណុចសូន្យ គ្មានរចនាសម្ព័ន្ធស្ថាប័ន ធនធានមនុស្ស សម្ភារៈ និងមធ្យោបាយ។ ក្រោមការដឹកនាំរបស់សម្តេច ក្រសួងបានលេចចេញជារូបរាង និងបន្តលូតលាស់ហើយបានបម្រើការយ៉ាងសកម្ម និងមានប្រសិទ្ធិភាពក្នុងការការពារប្រយោជន៍កម្ពុជាលើឆាកអន្តរជាតិ។ បន្ទាប់ពីសម្តេចទទួលបានការតែងតាំង ជានាយករដ្ឋមន្ត្រីនៅឆ្នាំ ១៩៨៥ សម្តេចតេជោ នៅតែជា អគ្គមគ្គុទេសក៍ដ៏ឆ្នើមបំផុត ជាប្រមុខការទូតកំពូលដ៏ឆ្នើមបំផុត ដែលមានចក្ខុវិស័យវែងឆ្ងាយ និងត្រឹមត្រូវបំផុតក្នុងការតម្រង់ទិស និងកំណត់មាគ៌ានយោបាយការបរទេសកម្ពុជាដែលបាននាំនាវាកម្ពុជាដល់ត្រើយសន្តិភាព បង្រួបបង្រួមជាតិ និងការអភិវឌ្ឍដែលពុំធ្លាប់មានក្នុងប្រវត្តិសាស្ត្រ៥០០ឆ្នាំចុងក្រោយរបស់កម្ពុជា។ ការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងសកលលោក តាមរយៈ ការចូលជាសមាជិកសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ឆ្នាំ១៩៩៩ និងការចូលជាសមាជិកអង្គការពាណិជ្ជ

កម្មពិភពលោក នៅឆ្នាំ២០០៤ គឺជាការកាច់ចង្កូតនយោបាយក្រៅប្រទេសចូលក្នុងសករាជថ្មី និងក្នុងកម្រិតមួយខ្ពស់។ ការធ្វើសមាហរណកម្មនេះ អនុញ្ញាតអោយកម្ពុជាដើរតួយ៉ាងសកម្មក្នុងការបង្កើនកិច្ចសហប្រតិបត្តិការសន្តិសុខ និងពាណិជ្ជកម្ម ការស្វែងរកដំណោះស្រាយវិបត្តិក្នុងតំបន់និងសកលលោក។ ទន្ទឹមនេះ មូលដ្ឋានគ្រឹះការទូតលើគ្រប់វិស័យ ក៏ត្រូវបានកសាង ដែលធ្វើអោយច្រកទ្វារការទូតកម្ពុជាកាន់តែមានវិសាលភាពធំទូលាយ ។

គ្រឹះនៃទំនាក់ទំនងការទូតនេះ ត្រូវបានបន្តពង្រីក ដោយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការលើកកម្ពស់តួនាទី និងកិត្យានុភាពរបស់កម្ពុជានៅលើឆាកអន្តរ ជាតិ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីមេត្រី!***

ក្នុងរយៈពេលជាង៧ឆ្នាំ ក្នុងតួនាទីជាប្រមុខការទូតរបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** វិស័យការទូតកម្ពុជាបានទទួលនូវកេរ្តិ៍ដំណែលដ៏ថ្លៃថ្លា។ ចាប់ផ្តើមពី (១)កំណែទម្រង់ផ្ទៃក្នុងស្ថាប័ន ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍ប្រែប្រួលឥតឈប់ឈរ និងស្មុគ្រស្មាញនៃស្ថានភាពសកលលោក និង (២) ការអនុវត្តយ៉ាងខ្ជាប់ខ្ជួនឥតងាករេ នូវគោលការណ៍ធំៗ នៃនយោបាយការបរទេស ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងក្រោមការដឹងដឹកនាំដ៏វាងវៃ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** (៣)គួបផ្សំនឹង ទេពកោសល្យការទូត របស់ឯកឧត្តម **ឧបនាយករដ្ឋមន្ត្រី** ដែលពោរពេញដោយភាពប៉ិនប្រសប់ បត់បែន ឈ្លាសវៃ មុតស្រួច និង ម៉ឺងម៉ាត់ បានរួមចំណែកយ៉ាងធំធេងធ្វើឱ្យកម្ពុជាទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ ។ ជាក់ស្តែង ដូចជាឆ្នាំ២០២២ គឺត្រូវបានទទួលស្គាល់ថា ជាឆ្នាំប្រកបដោយមោទនភាពសម្រាប់ប្រទេសកម្ពុជា ដែលទទួលបានជោគជ័យនៅខាងការទូតដោយមិនអាចប្រកែកបាន។

កំណែទម្រង់ផ្ទៃក្នុងស្ថាប័នក្នុងរយៈពេលជាង៧ឆ្នាំនេះ គឺសំដៅបង្កើនភាពមុតស្រួច កម្រិតវិជ្ជាជីវៈ សមត្ថភាព និងស្មារតីកក្តិចំពោះបុព្វហេតុជាតិ របស់អ្នកការទូតយើង ដើម្បីជាប្រយោជន៍សម្រាប់ជាតិមាតុភូមិ និង សំដៅកែលំអរលក្ខខណ្ឌ ប្រសិទ្ធិភាព និងបរិយាកាសការងារ និង ការកែទម្រង់ការងារក្រសួងឱ្យប្រកបដោយសមធម៌ ។ ខ្ញុំសូមគាំទ្រទាំងស្រុងនូវកំណែទម្រង់ដែលបានដាក់ចេញ និងដឹកនាំអនុវត្តដោយ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** ព្រោះជោគជ័យខាងការទូតអាចសម្រេចទៅបានពេញលេញ គឺមិនអាចកាត់ផ្តាច់បានទេពីវត្តមាននៃស្ថាប័នរឹងមាំមួយបានទេ។ ក្នុងន័យនេះ (១)ការបង្កើតឡើងនៃវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិដែលកន្លងមក បានដើរតួនាទីជាសារវន្តក្នុងការកសាងនិងលើកកម្ពស់សមត្ថភាព ទេពកោសល្យ និង ស្មារតីវិជ្ជាជីវៈ របស់មន្ត្រីការទូតកម្ពុជា (២)ការកែលម្អបរិស្ថាន ការងារ តាមរយៈការសាងសង់អគារធ្វើការថ្មី ការសាងសង់អគារបន្ថែម ការជួសជុលអគារចាស់ ការជួសជុលអគារស្ថានទូត (៣)ការតំលើងប្រាក់ខែនិងឈ្នួលផ្ទះរបស់មន្ត្រីការទូតនៅបរទេស និង ការផ្តល់មធ្យោបាយបំពេញការងារសម្រាប់មន្ត្រីទូតឱ្យប្រកបការងារដោយសេចក្តីថ្លៃថ្នូរ និងស័ក្តិសមជាតំណាងប្រទេសយើង សុទ្ធសឹងជាលទ្ធផលនៃកំណែទម្រង់ ដែលជាកត្តាចូលរួមកំណត់អំពីជោគជ័យធំៗខាងការទូត នាពេលកន្លងមក ដូចជា ជោគជ័យល្អឥតខ្ចោះនៃការធ្វើប្រធានអាស៊ាន ជោគជ័យនៃការធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំអាស៊ី-អឺរ៉ុប លើកទី១៣ (ASEM) ។

លទ្ធផលនៃកំណែទម្រង់ទាំងនេះ គឺជាសក្ខីភាពបញ្ជាក់អំពីការដឹកនាំអនុវត្ត ដ៏ឆ្នើម និងវាងវៃលើការងារកំណែទម្រង់ផ្ទៃក្នុងក្រសួង ប្រកបដោយជោគជ័យ របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានពុះពារ និងប្តូរផ្តាច់ក្នុងការស្វែងរកការគាំទ្រទាំងខាងនយោបាយ និង បច្ចេកទេស ជាពិសេស ការគាំទ្រ របស់ **សម្តេចតេជោ** រហូតទាល់តែសម្រេចបានចេញជារូបរាងនូវសមិទ្ធិផលទាំងនេះ សម្រាប់ទុកជាកេរ្តិ៍ដំណែល និងគុណប្រយោជន៍សម្រាប់ប្រទេសជាតិនិយាយជារួម និងមន្ត្រីការទូតយើងគ្រប់រូប

និយាយដោយឡែក។ ក្នុងនាមខ្ញុំជាអ្នកបន្តវេន ពិតជាកោតសរសើរ និងថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះសមិទ្ធិផលច្រើនអនេកដែលឯកឧត្តមបានផ្តួចផ្តើមបង្កើត និងបន្សល់ទុក។

ក្នុងគោលបំណងបន្តនិរន្តភាពនៃប្រសិទ្ធិភាពស្ថាប័ន ក៏ដូចជាធានាបានជោគជ័យថ្មីៗនាពេលខាងមុខ ការងារកំណែទម្រង់នឹងត្រូវអនុវត្តបន្តទៀតដើម្បីប្រែក្លាយក្រសួងការបរទេស ឱ្យទៅជាសេនាធិការដ៏រឹងមាំក្នុងវិស័យការទូតដើម្បីផលប្រយោជន៍ជាតិ ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស។

ដូចនេះ ខ្ញុំសូមគាំទ្រយ៉ាងពេញទំហឹង និងប្រកាសបន្តអនុវត្តកំណែទម្រង់ដែលបានដាក់ចេញដោយ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** ដោយក្នុងនោះ យើងនឹងបន្តអនុវត្តតាមការសម្រេចរបស់សន្និបាតបូកសរុបការងារឆ្នាំ២០២២ និងលើកទិសដៅ២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលរួមមានជាអាទិ៍ *(១)បន្តពង្រឹងដំណើរការដើម្បីបង្កើតសមិទ្ធិផលថ្មីៗរបស់វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិជាពិសេស បន្តយកចិត្តទុកដាក់ដល់ការបណ្តុះបណ្តាលធនធានមនុស្សខាងវិស័យការទូត ដើម្បីកសាងឲ្យបាននូវមន្ត្រីមានសមត្ថភាពខ្លាំង ស្អាតស្អំ វៃឆ្លាតនិងផ្តោតទៅលើប្រយោជន៍ជាតិ, (២)-ជំរុញការកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន និងបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រសួងចាំបាច់នានាទាំងផ្នែករឹង និងផ្នែកទន់ ដូចជាជំរុញសំណើគម្រោងសាងសង់អាគារធ្វើការបន្ថែមតាមការចាំបាច់, (៣) ពង្រីកសមត្ថភាពស្ថាប័ន ដោយបន្តយកចិត្តទុកដាក់ ក្នុងការបង្កើនចំនួនមន្ត្រីតាមដំណាក់កាល និងផ្តល់ការលើកទឹកចិត្តចំពោះបុគ្គលដែលមានសមត្ថភាព និងទេពកោសល្យ (៤)-បន្តជំរុញការស្នើសុំឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអនុវត្តឡើងវិញនូវការពិនិត្យតំឡើងប្រាក់បៀវត្សមន្ត្រីការទូត និងបុគ្គលិកនានាដែលបម្រើតាមស្ថានបេសកកម្មនៅក្រៅប្រទេសរៀងរាល់២ ឆ្នាំម្តង ដើម្បីអាចឆ្លើយតបសមស្របទៅនឹងស្ថានភាពសេដ្ឋកិច្ចជាក់ស្តែង។*

អំពីនយោបាយការបរទេសនាពេលកន្លងមក កម្ពុជា ឆ្លងកាត់បរិបទនៃការវិវត្តន៍ ប្រែប្រួលដ៏ជ្រាលជ្រៅ និងស្មុគ្រស្មាញនៃទំនាក់ទំនងអន្តរជាតិ ដោយសារសណ្តាប់ធ្នាប់ពិភពលោកបានងាកចេញពីប្រព័ន្ធឯកប៉ូល ទៅជាប្រព័ន្ធពហុប៉ូល ដោយក្នុងនោះ ការប្រកួតប្រជែងខាងភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ច និង យោធា មានភាពតានតឹងខ្លាំងឡើងរវាងមហាអំណាចធំបំផុតទាំងពីរ គឺ ចិន និងអាម៉េរិក ។ ការវិវត្តន៍ទាំងនេះ ពិតជាបង្កឱ្យមានសម្ពាធធ្ងន់ធ្ងរមកលើប្រទេសនានាក្នុងតំបន់និយាយជារួម និងកម្ពុជានិយាយដោយឡែក។ ឆ្លើយតបទៅនឹង សភាពការណ៍អន្តរជាតិទាំងនេះ កម្ពុជា នៅតែអនុវត្តស្របតាមរដ្ឋធម្មនុញ្ញ ជាក់ស្តែង ក្រោមការដឹកនាំផ្ទាល់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** កម្ពុជាបានធ្វើការសម្រេចដ៏ម៉ឺងម៉ាត់ និងត្រឹមត្រូវ ក្នុងបញ្ហាសង្គ្រាមនៅអ៊ុយក្រែន ដែលនេះគឺជាសក្ខីភាពដែលបានឆ្លុះបញ្ចាំងនូវ ជំហរឥតរវើករបស់កម្ពុជា ក្នុងការអនុវត្តនយោបាយការបរទេសឯករាជ្យរបស់កម្ពុជា ក្នុងការសម្រេចលើកិច្ចការការបរទេសដោយផ្អែកលើច្បាប់ និង និយាម អន្តរជាតិ ជាពិសេសការគោរពអធិបតេយ្យ បូរណភាពទឹកដី និងឯករាជ្យភាពរបស់រដ្ឋនានា។ បន្ថែមពីនេះ ក្នុងនាមប្រមុខការទូតកម្ពុជា ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** បានដឹកនាំក្រសួងអនុវត្តគោលនយោបាយការបរទេសក្នុងស្មារតីបុរេសកម្មដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនឹងការប្រឈមទាំងនេះ។ ក្នុងនោះ រួមមានការដាក់ចេញ និងអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ឆ្នាំ ២០២១-២០២៣ កិច្ចប្រឹងប្រែងក្នុងការជួយរកដំណោះស្រាយឱ្យវិបត្តិមីយ៉ាន់ម៉ា ការចូលរួមចំណែកក្នុងការទទួលបានជោគជ័យលើការគ្រប់គ្រងជម្ងឺកូវីដ ១៩ បេះដូងមនុស្សធម៌របស់កម្ពុជាក្នុងការចូលរួមជួយសម្រាលការលំបាកនៃការរីករាលដាលជម្ងឺកូវីដ ១៩ ជាដើម។

រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា នឹងបន្តដំណើរការក្នុងបរិបទនៃការប្រកួតប្រជែងខាងភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ច និង យោធា រវាងមហាអំណាច ធំបំផុតទាំងពីរ ដែលមានភាពតានតឹងខ្លាំងឡើង ។ ដូចនេះ នៅក្នុង

ស្ថានការណ៍ អន្តរជាតិវិវត្តន៍ បត់បែន ប្រែប្រួល យ៉ាងស្មុគស្មាញ និងឆាប់រហ័ស នេះ **ការបន្តវេនគឺទាមទារឱ្យមាននិរន្តរភាពនៃការអនុវត្តគោលនយោបាយការបរទេសរបស់កម្ពុជាដែលក្នុងនោះគឺ (១)បន្តគោរពឱ្យបានជាដាច់ខាតគោលការណ៍ធំៗដូចដែលមានចែងរដ្ឋធម្មនុញ្ញ** ពោលគឺ ប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹត អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតនៅលើពិភពលោក មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក ប្រឆាំងដាច់ខាតការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ទោះក្រោមរូបភាពណាក៏ដោយ មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយដែលមិនស្របនឹងអាព្យាក្រឹតភាពរបស់ខ្លួនឡើយ មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន។

**(២) អនុវត្តដោយឥតងាករេ នូវ កម្មវិធីគោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៧** នៃរដ្ឋសភា រួមមានការបន្តផ្តោតសារៈសំខាន់ និងផលប្រយោជន៍លើការងារចម្បងៗចំនួន៥ដែលរួមមាន **ទី១៖** បន្តការពារផលប្រយោជន៍ស្នូលរបស់កម្ពុជាដោយគោរព និងការពារយ៉ាងម៉ឺងម៉ាត់នូវរដ្ឋធម្មនុញ្ញ និងបន្តអនុវត្តការងារការទូតបុរេសកម្ម ដើម្បីទទួលបាននូវការគោរពដល់អធិបតេយ្យ បូរណភាពទឹកដី ឯករាជ្យ និង ការទទួលស្គាល់នូវបំណងប្រាថ្នា និងភាពចាំបាច់ក្នុងការរក្សាសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ **ទី២៖** បន្តអនុវត្តនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់អន្តរជាតិ ការគោរពនិយាម គោលបំណង និងគោលការណ៍នានា នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និង អាស៊ាន បន្តអនុវត្តការទូតទន់ភ្លន់, ប៉ុន្តែ ម៉ឺងម៉ាត់, បត់បែន និងថ្លឹងថ្លែង ស្របតាមការផ្លាស់ប្តូរផ្នែកយុទ្ធសាស្ត្រ, ភូមិសាស្ត្រនយោបាយតំបន់ និង ពិភពលោក ។ **ទី៣៖** រួមចំណែកកាន់តែសកម្មក្នុងកិច្ចប្រឹងប្រែងតំបន់ និងសកលលោក ដើម្បីថែរក្សា និងពង្រឹងសន្តិភាព ស្ថិរភាព និងវិបុលភាព បន្ត

ប្រយុទ្ធប្រឆាំងនឹង ផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ អំពើភេរវកម្ម ជំងឺឆ្លងនានា។ល។ **ទី៤៖** រីតចំណងខាងសេដ្ឋកិច្ចជាមួយដៃគូចាស់ និងថ្មី ជំរុញការទាក់ទាញវិនិយោគ, ស្វែងរកទីផ្សារសម្រាប់ផលិតផល និងគាំទ្រដល់ឧស្សាហកម្មនាំចេញ, លើកស្ទួយវិស័យទេសចរណ៍ និងវប្បធម៌ខ្មែរ ដោយផ្អែកលើប្រៀបខ្លាំងនៃសក្ដានុពលសេដ្ឋកិច្ច និងបេតិកភណ្ឌប្រវត្តិសាស្ត្រសម័យអង្គររបស់យើង, និងជំរុញអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងយន្តការសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ដើម្បីគាំទ្រផលិតកម្ម និងកំណើនសេដ្ឋកិច្ចក្នុងស្រុក ។ **ទី៥៖** បន្តយកចិត្តទុកដាក់ដល់ការបណ្ដុះបណ្ដាលធនធានមនុស្សខាងវិស័យការទូត ដែលត្រូវការពេល, មធ្យោបាយ, ធនធានបញ្ញា និងការលើកទឹកចិត្តសមស្រប ដើម្បីរក្សាទុក និងទាក់ទាញអ្នកមានសមត្ថភាព និងទេពកោសល្យ។

ក្នុងស្មារតីនៃការអនុវត្តស្របតាមនយោបាយការបរទេសដែលបានកំណត់ខាងលើ យើងនឹងបន្តអភិវឌ្ឍ និងអនុវត្ត **យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច** ដោយបន្តទាក់ទាញវិនិយោគបរទេសដែលមានការធានាចីរភាពបរិស្ថាន បន្តលើកកម្ពស់វិស័យ ទេសចរណ៍ និងជាអាទិភាព គឺ**លើកស្ទួយការផ្លាស់ប្ដូរ វប្បធម៌ និងកីឡា និងអភិវឌ្ឍ និងជំរុញនូវការទូតឌីជីថល។**

ដើម្បីទទួលបានលទ្ធផលពីភារកិច្ចខាងលើ ខ្ញុំនឹងខិតខំប្រឹងប្រែងអោយអស់កំលាំងកាយចិត្តបំពេញភារកិច្ច និងបេសកកម្មដ៏ឧត្តុង្គឧត្តមនេះ តាមគន្លងធម៌ ក្នុងមនសិការស្នេហាជាតិដ៏ស្មោះស្ម័គ្រ ដើម្បីបុព្វហេតុជាតិមាតុភូមិ។ ទន្ទឹមនេះ ខ្ញុំនឹងខិតខំឈ្វេងយល់ ពីយុទ្ធសាស្ត្រការទូត បទពិសោធន៍ដ៏សន្ទឹកសន្ធាប់ និងការធ្វើសេចក្ដីសម្រេចដ៏វាងវៃ និង ត្រងត្រាប់អនុវត្តតាមដំបូន្មានរបស់ **សម្ដេចអគ្គសេនាបតីតេជោ ហ៊ុន សែន** និងស្របតាមការចង្អុលបង្ហាញណែនាំ និងអនុសាសន៍ដឹកនាំ របស់ **ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត** ដែលមានចំណេះដឹង និងបទពិសោធន៍ដឹកនាំយោធា ។ ជាមួយគ្នា

ផងដែរ ខ្ញុំសូមស្នើសុំនូវ ការគាំទ្រផ្នែកស្មារតី ការចែករំលែកបទពិសោធន៍ជោគជ័យ ការផ្តល់ចក្ខុវិស័យ និងអនុសាសន៍ដ៏ថ្លៃថ្លា របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីមេត្រី!* ដើម្បីយើងអាចសម្រេចបានជោគជ័យនូវភារកិច្ច និងបេសកកម្មខាងលើ ជូនជាតិមាតុភូមិ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ការគាំទ្រ កិច្ចសហការ និងការចូលរួមចំណែករបស់ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិករបស់ក្រសួងការបរទេស និងសហប្រតិបត្តិការទាំងមូលជាកត្តាសត្យានុម័តដែលមិនអាចខ្វះបាន ។ ហេតុដូច្នេះ ខ្ញុំសង្ឃឹម និងសូមលើកទឹកចិត្ត ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ មេត្តាចូលរួមអនុវត្ត និងសហការ ដោយប្រើប្រាស់នូវបទពិសោធន៍ដ៏ទូលំទូលាយ និងបញ្ញាញាណ ក្នុងស្មារតីបុរសកម្មម្ចាស់ការ និងទទួលខុសត្រូវខ្ពស់ ដើម្បីរួមគ្នា សំរេចជោគជ័យ នូវបេសកកម្មដ៏ថ្លៃថ្លា និង ខ្ពង់ខ្ពស់ ដែលប្រមុខរាជរដ្ឋាភិបាលបានប្រគល់ឲ្យយើង។ ការចូលរួមអនុវត្ត និងសហការប្រកបដោយសាមគ្គីភាព ភាតរភាព និងការយោគយល់អធ្យាស្រ័យ របស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ នឹងមិនត្រឹមតែនាំមកនូវជោគជ័យសម្រាប់ក្រសួងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ឱកាសឱ្យយើងទាំងអស់អាចរួមគ្នាបន្តថែរក្សា និង អភិវឌ្ឍកេរ្តិ៍ដំណែលក្នុងវិស័យការទូតនេះសម្រាប់ជាតិមាតុភូមិ និងប្រជាជាតិរបស់យើងបន្តទៀត។

មុននឹងបញ្ចប់ ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់បំផុតគោរពជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានផ្តល់ទំនុកចិត្តតែងតាំងរូបខ្ញុំ។ តាមបណ្តាប្រទេសនានា រដ្ឋមន្ត្រីការបរទេសតែងតែត្រូវបានចាត់ទុកជា ប្រមុខការ ទូត។ ពិតណាស់ការលើកឡើងនេះជាការត្រឹមត្រូវ ប៉ុន្តែ សម្តេចតេជោ ទោះពុំស្ថិតក្នុងមុខតំណែងជានាយករដ្ឋមន្ត្រី និងជាប្រមុខរដ្ឋាភិបាលក៏ពិតមែន សម្រាប់រូបខ្ញុំ ខ្ញុំហ៊ាននិយាយថា **សម្តេចតេជោ** គឺ

នៅតែជាប្រមុខការទូតកំពូលដ៏ឆ្នើមបំផុតរបស់កម្ពុជាពិតប្រាកដែលមិនអាចប្រៀបផ្ទឹមបានឡើយ។

ទន្ទឹមនេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជាថ្មីម្តងទៀតដែរ ជូនចំពោះឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** ដែលតែងតែលើកទឹកចិត្ត និងយកចិត្តទុកដាក់ក្នុងការបង្ហាញផ្លូវដល់ខ្ញុំ ក្នុងអំឡុងពេលមុនការចូលកាន់តួនាទី ដឹកនាំ វិស័យការទូតនេះ។ ខ្ញុំ សូមគោរពកោតសរសើរ និងដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះ ការពុះពារ ប្រកបដោយអំណាត់អត់ធ្មត់ និងប្តូរផ្តាច់ក្នុងការស្វែងរកការគាំទ្រ. ទាំងខាងនយោបាយ និងបច្ចេកទេសដែលនាំដល់ការកកើតស្នាដៃ និងសមិទ្ធផល ដ៏សន្ធឹកសន្ធាប់ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់មន្ត្រីរាជការក្នុងវិស័យការទូតគ្រប់ជាន់ថ្នាក់។ ការដឹកនាំប្រកបដោយគុណធម៌ និងព្រហ្មវិហាធម៌របស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** នឹងនៅជិតជាប់ក្នុងការចងចាំរបស់ថ្នាក់ដឹកនាំ មន្ត្រីការទូត និងបុគ្គលិកគ្រប់ជាន់ថ្នាក់ ក្នុងមនោសញ្ចេតនានឹករលឹក និងអាឡោះអាល័យបំផុត។ ស្នាដៃ និងសមិទ្ធផលដែលបានបន្សល់ទុកដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** គឺជាកេរ្តិ៍ដំណែល ដែលថ្នាក់ដឹកនាំនិងមន្ត្រីគ្រប់ជាន់ថ្នាក់បានចងចាំទុកដោយក្តីដឹងគុណ និងបន្តថែរក្សា អនុវត្ត ក្នុងមនសិការស្មោះស្ម័គ្រ និងដើម្បីឧត្តមប្រយោជន៍ជាតិមាតុភូមិ និងប្រជាពលរដ្ឋ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សូមមានសុខភាពល្អបរិបូរណ៍ បញ្ញាញាណវាងវៃ និង កំលាំងពលំមាំមួន ដើម្បីបន្តនូវបេសកកម្មថ្លៃថ្លាក្នុងការបម្រើជាតិមាតុភូមិបន្តទៀត ហើយខ្ញុំក៏សូមជូនពរ ឯកឧត្តម លោកជំទាវ ឯកអគ្គរដ្ឋទូត ភ្ញៀវកិត្តយស អស់លោក លោកស្រី និងអង្គពិធីទាំងមូល ទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!